**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ...០០១............ស.ភ.រ

# សេចក្តីជូនដំណឹង

អនុលោមតាមសេចក្តីសម្រេចលេខ ៤១១២ មស.សករ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៧ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់សិស្ស និស្សិត និងមន្ត្រីរាជការទាំងអស់ ឱ្យបានជ្រាបថាសាលានឹងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៧ ចំនួន១២០នាក់ សម្រាប់ការបណ្តុះបណ្តាលឆ្នាំ២០១៧នេះ។

- លក្ខខណ្ឌនៃការជ្រើសរើស ៖ សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាឆ្នាំទី២ដោយជោគជ័យគ្រប់ជំនាញ និងមន្ត្រីរាជការដែលបានបម្រើការងាររយៈពេល៣ឆ្នាំ ឡើងទៅ។
- កាលបរិច្ឆេទ នៃការលក់ពាក្យនឹងចាប់ផ្តើមពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ តទៅ។
- កាលបរិច្ឆេទ នៃការទទួលពាក្យនឹងចាប់ផ្តើមពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង១៧ម៉៣០នាទី ជាពេលផុតកំណត់។
- ការប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅចុង ខែកុម្ភៈ ឆ្នាំ២០១៧ រីឯកាលបរិច្ឆេទជាក់ស្តែងនឹងត្រូវប្រកាសបិទផ្សាយជូននៅពេលក្រោយ។
- បញ្ជាក់៖ ពាក្យ០១ច្បាប់ តម្លៃ៤៥០០រៀល និងការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ៣៥០០០រៀល។

ចំពោះព័ត៌មានលម្អិតផ្សេងៗទៀត សូមបើកមើលគេហទំព័រសាលា www.era.cambodia.gov.kh ឬ ទំនាក់ទំនងជាមួយរដ្ឋបាលនៃសាលាភូមិន្ទរដ្ឋបាលរៀងរាល់ម៉ោងធ្វើការ ឬ តាមរយៈមន្ត្រីសាលាដូចមានរាយនាមខាងក្រោម ៖

- លោកស្រី ច្រឹង វណ្ណារ៉ា ទូរស័ព្ទលេខ ០១២ ៨៦១ ០៤៧
- លោកស្រី សេង សេរីវឌ្ឍនា ទូរស័ព្ទលេខ ០៨៨ ៨៨០ ៣៨៥៥
- លោក ងួន ស៊ីមួយ ទូរស័ព្ទលេខ ០១២ ៤២១ ០០១
- លោក អឹម ច័ន្ទសុភា ទូរស័ព្ទលេខ ០៩២ ១៦៦ ០០០

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៧

**នាយកសាលា**

**យក់ ប៊ុនណា**

**ចម្លងជូន:**

- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ខុទ្ទកាល័យឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រី ពេជ្រ ប៊ុនធិន
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន : អាគារលេខ ១៧ វិថីឧកញ៉ាឡឹកថ្កឡុង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658
អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ៤១១២ មស. ឃឃរ

# សេចក្តីសម្រេច
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៧

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ-បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្របក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- យោងសំណើរបស់នាយកសាលាភូមិន្ទរដ្ឋបាល ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

# សម្រេច

**ប្រការ ១** - ត្រូវបានអនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលមន្ត្រីក្រមការ លើកទី៧ ចំនួន ១២០នាក់ នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការតាមក្រសួង ស្ថាប័ន និងនិស្សិត។ បេក្ខជនដែលប្រឡងជាប់នឹងត្រូវរៀនរយៈពេល ១ឆ្នាំ។ កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅខែកុម្ភៈ ឆ្នាំ២០១៧។

**ប្រការ ២** - លក្ខខណ្ឌជ្រើសរើស ៖

- បេក្ខជនទាំងពីរភេទជានិស្សិតត្រូវមានអាយុយ៉ាងច្រើនបំផុត២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតទុតិយភូមិ បូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- បេក្ខជនទាំងពីរភេទជាមន្ត្រីរាជការត្រូវមានអាយុយ៉ាងច្រើនបំផុត៤០ឆ្នាំ ហើយបានបំពេញការងារយ៉ាងតិច ៣ឆ្នាំក្នុងមុខងារសាធារណៈ។
- ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅពេលប្រឡងជាប់ជាស្ថាពរ។
- ត្រូវមានលិខិតពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារបញ្ជាក់ថា មានកាយសម្បទាមាំមួន និងសុខភាពល្អបរិបូរណ៍ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។
- បញ្ជីបេក្ខជនដែលអនុញ្ញាតឲ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**ប្រការ ៣** - វិញ្ញាសាប្រឡងប្រជែងរួមមាន ៖ វិញ្ញាសាសរសេរលើកទី១ និងវិញ្ញាសាសរសេរលើកទី២

ក- វិញ្ញាសាសរសេរលើកទី១ ៖

សំណួរពហុចម្លើយ និងអធិប្បាយខ្លី "រយៈពេល ២ម៉ោង៣០នាទី "

មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឲ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២។

ខ- វិញ្ញាសាសរសេរលើកទី២ ៖

១- អធិប្បាយ ជ្រើសរើស ពាក់ព័ន្ធនឹងចំណេះដឹងទូទៅ ( ច្បាប់រដ្ឋបាល, សេដ្ឋកិច្ច, វប្បធម៌ទូទៅ) និងសំណួរខ្លី ពាក់ព័ន្ធនឹង ប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ, ភូមិសាស្ត្រ, សីលធម៌ ពលរដ្ឋវិទ្យា, អរិយធម៌វប្បធម៌ "រយៈពេល ៣ម៉ោង " មេគុណ ១

២- ភាសាអង់គ្លេស ឬភាសាបារាំង "រយៈពេល ១ម៉ោង ៣០នាទី" មេគុណ ១

**ប្រការ ៤** - វិញ្ញាសាសរសេរត្រូវរក្សាអនាមិកភាព។ វិញ្ញាសានីមួយៗត្រូវកែជាពីរលើក និងត្រូវផ្តល់ពិន្ទុលើ ១០០។

**ប្រការ ៥** - ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលា។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ ៦** - ការទទួលស្គាល់ជាសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល ត្រូវធ្វើដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ សិស្សត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ ៧** - ក្រុមប្រឹក្សាសាលា នាយកសាលាភូមិន្ទរដ្ឋបាល ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី … ខែ … ឆ្នាំ២០១៦

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ